

# ជ្រមុជទឹក!

Let's Read

The Asia Foundation



ថ្ងៃនេះ ផ្ទៃមេឃពណ៌ខៀវ មិនសូវមានរលក គឺល្អបំផុត
សម្រាប់ការមុជទឹក ។ ពួកយើងចេញកូនទូកមួយទៅ ដើម្បី
ការផ្សងព្រេងដ៏អស្ចារ្យ ។



នៅពេលដែលពួកយើងទៅដល់កន្លែងជ្រមុជទឹក ពួកយើងពិនិត្យសម្ភារៈទាំងអស់យ៉ាងប្រុងប្រយ័ត្ន ហើយចាប់ផ្តើមពាក់ជើងទា វ៉ែនតាហែលទឹក និងបំពង់ដកដង្ហើម។



នៅពេលដែលយើងចុះដល់ក្រោមទឹកភ្លាម ហ្វូងត្រីឆ្នូតលឿងនៅខ្ទង់ក៏បានមកស្វាគមន៍ពួកយើង។



មានសត្វយ៉ាងស្រស់ស្អាតជាច្រើនរស់នៅតាមផ្ទាំងផ្កាថ្មមួយនេះ ដូចជាត្រីឆ្នូត ត្រីសេក ត្រីប្រជៀវ និងខ្យងគ្មានស្នូកចម្រុះពណ៌។ បើចង់ដឹងបន្ថែមពីត្រីទាំងនេះ សូមមើលនៅផ្នែកចុងក្រោយនៃរឿង។



ត្រីត្រែទាំងនេះប្តូរពណ៌ ពេលពួកវាព្យាយាមលាក់ខ្លួនជាមួយ
ហ្វូងត្រីពណ៌លឿង ប៉ុន្តែអ្នកណាក៏អាចឃើញថា ពួកវាខុសពីត្រី
ដទៃក្នុងហ្វូងដែរ មែនឬទេ ?



យើងគួរតែនៅឱ្យឆ្ងាយពីត្រីតោ ព្រោះទ្រនុងរបស់វាមានពិស។



ត្រីត្លុកទាំងនេះព្យាយាមការពារអាណេម៉ូនដែលជាជម្រករបស់វា តែទីបំផុតពួកវាក៏ព្រមឱ្យខ្ញុំថតរូបមួយចំនួនដែរ។



យើងបានឃើញអន្ទង់ពញ្លាក់ដែលកំពុងតែឱ្យត្រីតូចៗសម្អាតធ្មេញ
ហើយត្រីតូចមួយគូទៀតក៏ចង់មកសម្អាតឱ្យពួកយើងដែរ ។



យើងឃើញមានត្រីតុកកែ និងតាអន់សមុទ្រ។ យើងថែមទាំងឃើញត្រីក្រហមអុជៗ និងមឹកកំពុងលេងបិទពួនទៀតផង ។



មឹកឈ្នះ។ វាពូកែលាក់ខ្លួនណាស់។ ឯត្រីបំពង់វិញក៏មិនចាញ់ដែរ ។ តើអ្នកអាចរកឃើញត្រីបំពង់បន្លាទាំងពីរក្នុងរូបនេះដែរឬទេ ?



យើងបានហែលកាត់ត្រីឆ្លាមចុងព្រុយពណ៌សមួយគូដែលដេក
នៅបាតសមុទ្រ។ ពួកវាមិនសាហាវទេ ដូចនេះពួកយើងក៏ហែល
ទៅមើលឱ្យជិត។



ពួកយើងបានហែលតាមសត្វកន្ធាយនេះមួយសន្ទុះ ពេលដែលវាកំពុងហែលជុំវិញផ្កាថ្ម ដើម្បីរកសត្វអេប៉ុងសម្រាប់ជាអាហារថ្ងៃត្រង់។



ពេលដែលយើងហែលត្រលប់ទៅទូកវិញ ពួកយើងរំភើបណាស់ដែលបានឃើញត្រីបបែលហែលទទះស្លាប ហាក់ដូចជាហោះក្នុងទឹកសមុទ្រជាមួយត្រីរ៉េម៉ូរ៉ាមួយគូ។



នៅពេលដែលយើងគិតថា លែងមានអ្វីពិសេសជាងនេះហើយ ស្រាប់តែពួកយើងប្រទះឃើញសត្វផ្សោតសមុទ្រមួយកំពុងតែ សីុស្មៅ។



ពិតជាបទពិសោធន៍ដ៏អស្ចារ្យមែន! ខ្ញុំចង់មុជទឹកសមុទ្រម្ដងទៀតណាស់ !



ផ្កាថ្មត្រូវបានគេចាត់ទុកជារុក្ខជាតិផង និងជាសត្វផង ។ សារាយតូចៗរាប់ពាន់រស់នៅក្នុងផ្កាថ្ម និងផ្តល់ថាមពលឱ្យពួកវាលូតលាស់ ។ ពួកវាមានឆ្អឹងពីខាងក្រៅរឹងមាំ ហើយដុះចេញជារាងផ្សេងៗ ។ ប្លង់តុងជាប្រភពអាហារយ៉ាងសំខាន់សម្រាប់សត្វក្នុងសមុទ្រ ។ វាប្រមូលផ្តុំដោយសារាយ បាក់តេរី សត្វល្អិតៗ ពងត្រី និងកូនក្អកនៃត្រីធំៗដែលអណ្តែតតាមខ្សែទឹកសមុទ្រ ។ ផ្កាយសមុទ្រមើលទៅដូចជារុក្ខជាតិតែតាមពិតពួកវាជាសត្វនោះទេ។ ពួកវាប្រើប្រមោយរាងដូចស្លាបសត្វដើម្បីចាប់ និងស៊ីប្លង់តុងដែលអណ្តែតមកជិត ។



ត្រីសេកមានធ្មេញមាំរាងដូចចំពុះសេក ដែលអាចកោសយកសារាយចេញពីផ្កាថ្មបាន ។ សត្វមួយចំនួនស៊ីទាំងផ្កាថ្មតែម្តងហើយជុុះមកវិញជាគ្រាប់ខ្សាច់ល្អិតៗដែលទឹកសមុទ្រនាំយកទៅចាក់លើឆ្នេរខ្សាច់ដ៏សស្អាត ។ ត្រីត្លុក និងអាណោម៉ូនរស់នៅដោយពឹងអាស្រ័យគ្នាទៅវិញទៅមក ។ ត្រីត្លុកជួយសម្អាតដៃរបស់អាណោម៉ូន និងទាក់ទាញត្រីដទៃមកធ្វើជាចំណីរបស់អាណោម៉ូន។ ឯអាណោម៉ូនវិញក៏អនុញ្ញាតឱ្យត្រីត្លុកពួនក្នុងដៃដោយមិនឱ្យជាតិពុលប៉ះលើត្រីទាំងនោះទេ ។ កូនត្រីសម្អាតជាត្រីតូចៗដែលជួយសម្អាតត្រីធំដោយពួកវាស៊ីបរាសិត និងស្បែកដែលងាប់ៗ ។ ត្រីធំៗចំណាំត្រីទាំងនេះដោយពណ៌របស់វា និង

របៀបដែលពួកវាហែលដូចជាកំពុងរាំអ៊ីចឹង ។



មឹកលាក់ខ្លួនដោយប្តូរពណ៌ និងក្រឡាលើខ្លួន។ វាតែងតែធ្វើសំបុកក្នុងថ្មប៉ប្រះទឹក ឬក៏កប់ខ្លួនក្នុងខ្សាច់តែម្តង។ ត្រីបំពង់បន្លាតែងតែហែលជាគូ ដោយយកក្បាលចុះក្រោម និងលាក់ខ្លួនក្នុងស្មៅ ផ្កាថ្ម ឬផ្កាយសមុទ្រ។ ពួួកវាក៏ដូចមឹកដែរ គឺវាអាចប្តូរពណ៌ដើម្បីលាក់ខ្លួនបាន។ ត្រីឆ្លាមចុងព្រុយពណ៌ស មានខ្លួនតូច ក្បាលធំ ហើយមានពណ៌សនៅចុងព្រុយខ្នង និងកន្ទុយ។ ពួកវាចេញរកចំណីពេលយប់ និងដេកនៅពេលថ្ងៃ ។



សត្វកន្ធាយមានខ្លួនសំប៉ែត ស្នូកមានស្នាមនៅផ្នែកខាងៗ ហើយមានរាងស្រួច វាមានមាត់ដូចចំពុះសត្វស្ទាំង។ ត្រីបបែល ជាប្រភេទត្រីធំ មានព្រុយរាងដូចជាស្លាបសងខាងខ្លួនរបស់វា។ ព្រុយធំរបស់វាជួយឱ្យវាហែលបានយ៉ាងងាយនៅក្នុងទឹក។ ព្រុយត្រីបបែលខ្លះមានប្រវែងរហូតដល់៧ម៉ែត្រឯណោះ! ផ្សោតសមុទ្រជាថនិកសត្វដែលរស់ក្នុងទឹក ហើយវាស៊ីរុក្ខជាតិជាអាហារ។ គេក៏អាចហៅវាថា គោសមុទ្រដែរ។

Brought to you by

The Asia Foundation

Let's Read is an initiative of The Asia Foundation's Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*DIVE!*, Published by Pratham Books, © Pratham Books. Released under CC BY 4.0.

This work is a modified version of the original story. © The Asia Foundation, 2018. Some rights reserved. Released under CC BY 4.0.

For full terms of use and attribution, http://creativecommons.org/licenses/by/4.0/
Contributing translators: Sodany Ouch